**ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា**

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៣

# ជប៉ុនផ្តល់ ១៨៨,៩៦៣ ដុល្លារអាមេរិកដើម្បីលើកស្ទួយមជ្ឈមណ្ឌលសិក្សាសហគមន៍តាមជនបទនៃប្រទេសកម្ពុជា



ក្រោមគ្រោងការណ៍នៃជំនួយឧបត្ថម្ភឥតសំណងសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុនរដ្ឋាភិបាលជប៉ុនបានផ្តល់ទឹកប្រាក់សរុបចំនួន១៥,៤៩៤,៩៦៦យ៉េន (ប្រមាណ១៨៨,៩៦៣ ដុល្លាអាមេរិក)ដល់អង្គការសន្តិស្ម័គ្រចិត្ត(SVA)។ កិច្ចសន្យាផ្តល់ជំនួយត្រូវបានចុះហត្ថលេខាដោយឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងលោកស្រីយ៉ាម៉ាម៉ូតូ អេរី នាយិកាអង្គការ SVA ដើម្បីអនុវត្តគម្រោង លើកស្ទួយមជ្ឈមណ្ឌលសិក្សាសហគមន៍នៅតាមតំបន់ជនបទ នៃប្រទេសកម្ពុជា។



ប្រជាជន ក្នុងឃុំនីពេជ



ប្រជាជន ក្នុងឃុំរោងគោ

ក្នុងគម្រោងនេះ SVAនឹងសាងសង់មជ្ឈមណ្ឌលសិក្សាសហគមន៍ រួមទាំងបំពាក់គ្រឿងសង្ហារឹមចំនួនពីរ ក្នុងឃុំនីពេជនៃខេត្តកំពង់ធំ និងឃុំរោងគោនៃខេត្តសៀមរាប។ តាមរយៈគម្រោងនេះ ប្រជាជនជាង៩,000 នាក់នៃឃុំជនបទទាំង២នេះនឹងអាចរៀនអាន និង សរសេរដើម្បីកែលម្អជំនាញប្រចាំជីវិតរបស់ពួកគេ។ ជាងនេះទៅទៀត SVA នឹងផ្តល់វគ្គបណ្តុះបណ្តាលអំពីកម្មវិធីពង្រឹងសមត្ថភាពដល់ថ្នាក់គ្រប់គ្រង និង បុគ្គលិកនៃមជ្ឈមណ្ឌលសិក្សាសហគមន៍ដើម្បីការសិក្សាប្រកបដោយប្រសិទ្ធភាព។

កម្មវិធីជំនួយឥតសំណង សម្រាប់គម្រោងរបស់ អង្គការក្រៅរដ្ឋាភិបាលជប៉ុន បានចាប់ផ្តើមនៅប្រទេសកម្ពុជាតាំងពីឆ្នាំ ២០០២ ដើម្បីគាំទ្រដល់សកម្មភាពរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុនក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីជួយដល់ការអភិវឌ្ឍន៍ និងស្តាបនាប្រទេសកម្ពុជាឡើងវិញនៅតាមកំរិតមូលដ្ឋាន។ ចាប់តាំង

ពីឆ្នាំ២០០២មក រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង ១៩.៥លានដុល្លាអាមេរិក ដល់គម្រោងចំនួន ៧៤ គម្រោង របស់អង្គការក្រៅរដ្ឋាភិបាលជប៉ុនដែលផ្តោតសំខាន់ទៅលើវិស័យអប់រំនៅកម្រិតមូលដ្ឋាន វិស័យសុខាភិបាល វិស័យកសិកម្ម និងសកម្មភាពបោសសំអាតមីន។ គម្រោងនេះគឺជាគម្រោងទី៣ តាមរយៈគ្រោងការណ៍នៃជំនួយនេះសម្រាប់ឆ្នាំសារពើពន្ធឆ្នាំ២០១៣ របស់ជប៉ុន (មេសា២០១៣ដល់មិនា ២០១៤)។



---


*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*

*ទូរស័ព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០*

*អ៊ីមែល: eco.jpn@.pp.mofa.go.jp*

*គេហទំព័រ: http://www.kh.emb-japan.go.jp*